មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក

ភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣

## ម.ស.ម.ក បង្ហាញពីការព្រួយបារម្ភចំពោះការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ និងជួបប្រជុំប្រព្រឹត្តដោយនគរបាលក្នុងខេត្តបាត់ដំបង

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បង្ហាញពីការព្រួយបារម្ភជាខ្លាំងចំពោះការចាប់ខ្លួនក្មេងជំទង់ប្រុស ១០នាក់ និងក្មេងជំទង់ស្រី ៨នាក់ ក្នុងខេត្តបាត់ដំបង កាលពីថ្ងៃសៅរ៍ ដោយគ្រាន់តែពួកគេជួបប្រជុំគ្នាក្នុងទីសាធារណៈ ហើយបានពាក់អាវយឺតដូចៗគ្នា ក្នុងគោលបំណងផ្សព្វផ្សាយពីក្រុមប្រជាប្រិយរបស់គេ (*សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ទំព័រទី៣)។ អាវយឺតនោះមានពាក្យថា "កុំខ្លាច" និងរូបសញ្ញាក្បាលខ្មោចដែលមានអណ្តាតភ្លើង។ ដោយគិតថាពួកគេជាក្រុមជើងកាង នគរបាលបានឃុំខ្លួនពួកគេរយៈពេលមួយយប់ រួចដោះលែងពួកគេបន្ទាប់ពីពួកគេត្រូវបាន "អប់រំ" និងបានសន្យាថាពួកគេនឹងមិនប្រព្រឹត្ត "បទល្មើស" ក្នុងការពាក់អាវយឺតដូចៗគ្នានេះទៀតទេ។

ក្រុមយុវជនទាំងនេះមិនបានប្រព្រឹត្តបទល្មើសអ្វីក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ (ក្រមព្រហ្មទណ្ឌ) នោះទេ ប៉ុន្តែផ្ទុយមកវិញពួកគេគ្រាន់តែអនុវត្តនូវសិទ្ធិសេរីភាពបញ្ចេញមតិ និងជួបប្រជុំរបស់គេតែប៉ុណ្ណោះ។ សិទ្ធិសេរីភាពបញ្ចេញមតិ ដែលរួមមានការបញ្ចេញមតិតាមរយៈជម្រើសនៃសម្លៀកបំពាក់ គឺត្រូវបានធានាក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) និងក្នុងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.ស.អ.ព.ន) ដែលបានចុះសច្ចាប័នដោយកម្ពុជានៅឆ្នាំ ១៩៩២។ សិទ្ធិសេរីភាពនៃការជួបប្រជុំគឺក៏បានធានាផងដែរ ក្នុងមាត្រា៤១ នៃ រដ្ឋធម្មនុញ្ញ ក៏ដូចជាក្នុងមាត្រា២១ នៃ ក.ស.អ.ព.ន ផងដែរ។ សិទ្ធិទាំងនេះ អាចត្រូវបានរឹតបន្តឹង ក្នុងករណីមួយចំនួនប៉ុណ្ណោះ ប៉ុន្តែ យុវជនទាំងនេះមិនបានបង្ហាញពីការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌សាធារណៈ ឬសន្តិសុខជាតិ នៅក្នុងសកម្មភាពរបស់ពួកគេនោះទេ។ បន្ថែមពីលើនោះទៀត ក៏មិនឃើញមាននូវផលប្រយោជន៍សាធារណៈណាដែលកើតមានដោយសារការចាប់ខ្លួន និងឃុំខ្លួនរបស់ពួកគេដែរ ដូច្នេះ ចំណុចទាំងពីរនេះគឺពិតជាបានរំលោភបំពានដល់សិទ្ធិសេរីភាពបញ្ចេញមតិ និងជួបប្រជុំរបស់ពួកគេ។

ម.ស.ម.ក ជឿជាក់ថាករណីនេះបង្ហាញអំពីគ្រោះថ្នាក់ដែលបង្កើតឡើងដោយ គោលនយោបាយភូមិឃុំមានសុវត្ថិភាព (គ.ភ.ឃ.ស) ដែលជាសេចក្តីបង្គាប់នីតិប្រតិបត្តិកាលពីឆ្នាំ ២០១០ ស្នើដោយក្រសួងមហាផ្ទៃ ដែលត្រូវបានអនុវត្តដោយនគរបាលហាក់ដូចជាសេចក្តីបង្គាប់នេះ ជាច្បាប់ដែលអនុម័តតាមលទ្ធិប្រជាធិបតេយ្យដោយរដ្ឋសភាពជាតិ។ ថ្វីបើសេចក្តីបង្គាប់នេះមិនមែនជាក្រមច្បាប់ក្តី គ.ភ.ឃ.ស ត្រូវបានអនុវត្តក្នុងករណីមួយចំនួន ដែលបំពាននឹងច្បាប់សំខាន់ៗដូចជា ក្រមព្រហ្មទណ្ឌ។ ក្នុងចំណោមសេចក្តីណែនាំផ្សេងៗ គ.ភ.ឃ.ស ស្នើនូវវិធានការណ៍ដើម្បីបង្រ្កាបសកម្មភាពជើងកាងនៅកម្ពុជា ដូចជា ស្នើឲ្យម្ចាស់សណ្ឋាគារ ឬម្ចាស់ក្លឹបឲ្យរាយការណ៍ពីក្រុមយុវជនវ័យក្មេងដែល "ដើរ

ក្រវែល" ទីកន្លែងរបស់ពួកគេ។ ការណ៍នេះហាក់ដូចជាបង្ហាញថា នគរបាលនៅខេត្តបាត់ដំបងត្រូវបានជំរុញទឹកចិត្តដោយ គ.ភ.ឃ.ស ដើម្បីចាប់ខ្លួន ឃុំខ្លួន និង "អប់រំ" យុវជនដែលគ្មានកំហុសទាំង១៨នាក់នេះ។

អ្វីដែលសំខាន់គឺថាយុវជនមិនគួរត្រូវបានចាត់ថាជាក្រុមជើងកាង និង "ដើរក្រវែល" នោះទេ ផ្ទុយទៅវិញពួកគេគួរតែត្រូវបានគោរពថាពួកគេជាប្រជាពលរដ្ឋ ដែលអនុវត្តនូវសេរីភាពនៃការជួបប្រជុំ ដែលធានាដោយច្បាប់ជាតិ។ ការណ៍ដែលការប្រមូលផ្តុំរបស់យុវជនវ័យក្មេងត្រូវបានចាត់ទុកខុសគ្នានឹងការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋវ័យចំណាស់ដទៃនោះ គឺពិតជាបានរំលោភបំពានសិទ្ធិរួចផុតពីការរើសអើងដែលការពារដោយមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។ បន្ថែមពីលើនោះ សិទ្ធិដែលត្រូវបានសន្មត់ថាគ្មានទោសមុនការផ្តន្ទាទោស ដែលថានាដោយ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ តម្រូវថាយុវជនទាំងនោះមិនគួរត្រូវបានចាត់ទុកថាជាសមាជិកក្រុមជើងកាង ដោយអវត្តមាននូវភស្តុតាងជាក់ស្តែងបង្ហាញថាគេបានពាក់ព័ន្ធក្នុងសកម្មភាពជើងកាងនោះទេ។ បន្ថែមពីលើនោះ ក្នុងពេលដែលពួកគេកំពុងតែធំលូតលាស់បែបនេះ មានសារៈសំខាន់ណាស់ដែលថាសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដោយសេរីត្រូវបានទទួលស្គាល់ថាជាធាតុផ្សំសំខាន់ក្នុងការទទួលស្គាល់ខ្លួនឯង និងជាជំហានដ៏សំខាន់ក្នុងការក្លាយទៅជាសមាជិកដែលចាស់ទុំ និងចូលរួមក្នុងសង្គមប្រជាធិបតេយ្យ។

**ឆ្លើយតបទៅនឹងករណីនេះ មន្ត្រីសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិ របស់ ម.ស.ម.ក សន រ៉ាមណា បានមានប្រសាសន៍ថា ៖**

*"ការចាប់ខ្លួនយុវជនទាំង១៨នាក់នេះ បញ្ជាក់ពីវិធានការដែលមានលក្ខណៈធ្ងន់ធ្ងរ និងមានការភ័យខ្លាចរបស់រដ្ឋកម្ពុជាក្នុងការបង្ក្រាបបទល្មើស និងបញ្ហាសង្គម ដោយដោះដូរនឹងសិទ្ធិមនុស្សជាមូលដ្ឋាន។ យុវជនកម្ពុជាគួរតែត្រូវជំរុញចិត្តដើម្បីបង្ហាញពីខ្លួនគេដោយសេរី ជាជាងរងនូវការបង្ក្រាបមកលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពួកគេ ដូចករណីនេះជាដើម។ យើងសង្ឃឹមថាករណីអកុសលនេះនឹងជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាចេញនូវសេចក្តីបញ្ជាក់លើស្ថានភាពតតិយុត្តរបស់ គ.ភ.ឃ.ស ទៅកាន់អាជ្ញាធរសាធារណៈទាំងអស់ រួមទាំងមន្ត្រីនគរបាលផងដែរ។ ធ្វើបែបនេះ មន្ត្រីនគរបាលនឹងមានការយល់ដឹងបន្ថែមទៀតពីកម្រិតនៃការអនុវត្តន៍ច្បាប់ អនុញ្ញាតឲ្យពួកគេអភិវឌ្ឍនូវគោលនយោបាយបង្ក្រាបបទល្មើសដែលមានប្រសិទ្ធភាព ហើយរួមជាមួយគ្នាដែរនោះត្រូវអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលបានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ" ។*

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង កញ្ញា សន រ៉ាមណា មន្ត្រីសម្របសម្រួលគម្រោង តាមរយៈទូរសព្ទ +៨៥៥(០) ១៧ ៦៥ ៥៥ ៩១ ឬអ៊ីម៉ែល ramanasorn@cchrcambodia.org ឬទីប្រឹក្សា កញ្ញា អូឡា ខេលី តាមរយៈទូរសព្ទ +៨៥៥ (០) ៦៧ ៧២ ៧០ ២៥ ឬអ៊ីម៉ែល orla.kelly@cchrcambodia.org ។

-ចប់-

<u>បណ្ណាធិការ</u>

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់នៃ សិទ្ធិ និងសេរីភាព។#